អង្គភាពគាំទ្រកម្មវិធី នៃ គ.ជ.អ.ប

| ចូល | ម៉ោង: |
|---|---|
| | ថ្ងៃទី 18 ខែកុម្ភៈឆ្នាំ 2012 |
| | លេខ: 172 |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ០៣ សរណន

សារាចរណែនាំ

ស្តីពី

# ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣

## I. សេចក្តីផ្តើម

១- មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ បានបែងចែកកិច្ចដំណើរការនៃការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំជា៣ ដំណាក់កាលគឺ (១) *ដំណាក់កាលទី១:* ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាពីខែមីនា ដល់ខែឧសភា (២) *ដំណាក់កាលទី២:* ការរៀបចំកញ្ចប់ថវិកាពីខែមិថុនា ដល់ខែកញ្ញា និង(៣) *ដំណាក់កាលទី៣:* ការអនុម័តថវិកា ពីខែតុលា ដល់ខែធ្នូ។ ដើម្បីធានាការអនុវត្តច្បាប់នេះ និងដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃការរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ រាជរដ្ឋាភិបាលត្រូវចេញសារាចរណែនាំពីរគឺ ***សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា*** នៅដើមខែមេសា សម្រាប់ដំណាក់កាលទី១ និង ***សារាចរណែនាំស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ*** នៅដើមខែមិថុនា សម្រាប់ដំណាក់កាលទី២។ ដូច្នេះសារាចរនេះ គឺជាមគ្គុទ្ទេសក៍សម្រាប់ណែនាំ និងជាជំនួយដល់ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣-២០១៥ ដល់គ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញគ្រប់រាជធានី ខេត្តទាំងអស់សម្រាប់រដ្ឋបាលថ្នាក់ជាតិ។ ដោយឡែក សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវចេញដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។

២- ផែនការយុទ្ធសាស្ត្រថវិកាគឺជាឧបករណ៍ និងជាយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការប្រើប្រាស់ថវិកាតាមរយៈការជួយតម្រង់ និងជំរុញឱ្យការបែងចែកថវិកាចំទិសដៅ ការវិភាជថវិកាបម្រើឱ្យសកម្មភាពអាទិភាព និងការវិភាជថវិកាមានភាពជាក់ស្តែង ដើម្បីសម្រួចរាល់ចំណាយរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត បម្រើទាំងស្រុង និងសម្រេចឱ្យបាននូវគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់ក្រសួង ស្ថាប័ននីមួយៗ ក៏ដូចជាគោលនយោបាយជាយុទ្ធសាស្ត្រ និងអាទិភាពរបស់វិស័យនីមួយៗ សម្រាប់រួមចំណែកសម្រេចឱ្យបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-**

២០១៣។ ផែនការយុទ្ធសាស្ត្រថវិកានេះ គឺជាមូលដ្ឋានដ៏សំខាន់សម្រាប់ (១) ផ្សារភ្ជាប់គោលនយោបាយទៅនឹងថវិកា (២) បង្កើនសុក្រឹតភាពក្នុងការគណនាតម្រូវការថវិកា (៣) ជាមូលដ្ឋានសម្រាប់ពន្យល់ និងធ្វើអំណះអំណាងលើតម្រូវការថវិកា (៤) ធានានិរន្តរភាពនៃកម្មវិធី និងយុទ្ធសាស្ត្រអាទិភាព និង(៥) ជាមូលដ្ឋានសម្រាប់វាយតម្លៃលើអាទិភាពក្នុងការកំណត់កញ្ចប់ និងការវិភាជថវិកា ។ ដូច្នេះ គឺជាតម្រូវការចាំបាច់ដែលគ្រប់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ ធ្វើបច្ចុប្បន្នភាព***ផែនការយុទ្ធសាស្ត្រថវិកា***ជារៀងរាល់ឆ្នាំ។

៣- ផែនការយុទ្ធសាស្ត្រថវិកានេះ មិនត្រឹមតែបាននឹងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់ក្នុងការបង្កើនប្រសិទ្ធភាព នឹងភាពស័ក្តិសិទ្ធិក្នុងការវិភាជ ការប្រើប្រាស់ និងការគ្រប់គ្រងថវិកាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបាន និងកំពុងក្លាយជាឧបករណ៍ និងយន្តការដ៏សំខាន់សម្រាប់ការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ឱ្យទៅជាថវិកាមួយឯកភាព និងគ្រប់ជ្រុងជ្រោយ។ ***ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះអាចប្រព្រឹត្តទៅដោយរលូន និងគ្រប់ជ្រុងជ្រោយជាពិសេស ដោយផែនការយុទ្ធសាស្ត្រថវិកានេះតម្រូវឱ្យផ្សារភ្ជាប់ទៅនឹងគោលនយោបាយយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ និងបញ្ចូលទាំងថវិកាចរន្ត និងថវិកាមូលធន រួមទាំងថវិកាជាតិ និងថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ផងនោះ ក្រសួងស្ថាប័ននីមួយៗត្រូវប្រើប្រាស់ក្រុមការងារថវិការបស់ខ្លួនដែលមានសមាសភាពមកពីនាយកដ្ឋានហិរញ្ញវត្ថុ/និងគណនេយ្យ នាយកដ្ឋានផែនការ និងអង្គភាពគ្រប់គ្រងគម្រោង***។ ក្រុមការងារនេះ ត្រូវរៀបចំផែនការយុទ្ធសាស្ត្រថវិកាដោយផ្អែកលើគោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័នដើម្បីដាក់ជូនរដ្ឋមន្ត្រី ឬប្រធានស្ថាប័នពិនិត្យ សម្រេច និងចុះហត្ថលេខា។ ***គ្រប់ក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ ២០១៣-២០១៥ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកា) ឱ្យបានត្រឹមថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១២*** ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យ និងអាចអញ្ជើញតំណាងក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តមកពិគ្រោះ និងសាកសួរព័ត៌មានបន្ថែមក្នុងករណីចាំបាច់។ ក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តដែលមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកាតាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសិទ្ធិវិភាជកញ្ចប់ថវិកាដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកា និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

## II. ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

### ក. ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

៤- ជាទូទៅ ស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅឆ្នាំ២០១១ មានលក្ខណៈល្អប្រសើរ ហើយបានងើបឡើងវិញយ៉ាងខ្លាំងក្លា ។ តាមការគណនាជាបឋមរបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការបានបង្ហាញថា កំណើនសេដ្ឋកិច្ចនៅឆ្នាំ២០១១ សម្រេចបានក្នុងរង្វង់៦,៩% ក្នុងនោះ វិស័យកសិកម្មបានបន្តមានកំណើនប្រមាណ ៣,៣% ទោះជាត្រូវបានជួបប្រទះគ្រោះទឹកជំនន់ក្តី វិស័យឧស្សាហកម្មមានកំណើន១៤,៣% និងវិស័យសេវាកម្មមាន កំណើន៥%។

៥- តាមការព្យាករណ៍ដោយប្រយ័ត្នប្រយែង និងដោយផ្អែកលើនិន្នាការសេដ្ឋកិច្ចដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ២០១២ នេះអាចនឹងបន្តសម្រេចបានក្នុងរង្វង់៧% គឺលើសពីការគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២ ដែលបានព្យាករណ៍ត្រឹមតែ៦,៥%។ កំណើននេះនឹងបានមកពីកំណើនវិស័យកសិកម្មប្រមាណ៣,៩% ដោយសារការបន្តកើនឡើងនៃដំណាំស្រូវ កៅស៊ូ និងបណ្តាដំណាំដែលកំពុងមានសក្តានុពលនៅលើទីផ្សារដទៃទៀតដូចជា ពោត សណ្តែក និងដំឡូងមីជាដើម។ វិស័យឧស្សាហកម្ម នឹងមានកំណើន១០,៥% ដោយសារការបន្តកើនឡើងនៃផ្នែកវាយនភណ្ឌ ការកែច្នៃ សំណង់ និងអគ្គិសនី។ វិស័យសេវាកម្មនឹងមានកំណើន៦,៤% ដែលកំណើននេះបានមកពីការបន្តមានកំណើននៃវិស័យទេសចរណ៍ ហិរញ្ញវត្ថុ និងធនាគារ អចលនវត្ថុ និងពាណិជ្ជកម្ម ព្រមទាំងការដឹកជញ្ជូន និងទូរគមនាគមន៍។

៦- កំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៣ តាមការព្យាករណ៍អាចនឹងបន្តសម្រេចបានក្នុងរង្វង់៧%។ កំណើននេះនឹងបានមកដោយសារវិស័យកសិកម្មអាចនឹងបន្តរក្សាកំណើនបានក្នុងរង្វង់៣,៩% ពិសេសគឺដោយសារការបន្តកើនឡើងនៃដំណាំស្រូវដែលជាសមិទ្ធផលនៃការអនុវត្តគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ និងលទ្ធភាពនៃការនាំចេញកសិផលដទៃទៀតដែលកំពុងមានសក្តានុពលលើទីផ្សារ ដូចជាកៅស៊ូ ពោត សណ្តែក និងដំឡូងមី ព្រមទាំងបណ្តាកសិផលបន្ទាប់បន្សំផ្សេងៗទៀត។ វិស័យឧស្សាហកម្មអាចនឹងមានកំណើនប្រមាណ១០,២% ដោយរំពឹងថាវិស័យវាយនភណ្ឌនឹងអាចកើនឡើងប្រមាណ១១,៦% យោងលើការចាប់ផ្តើមងើបឡើងវិញនៃសេដ្ឋកិច្ចសហរដ្ឋអាមេរិក និងសញ្ញាវិជ្ជមាននៃសេដ្ឋកិច្ចអឺរ៉ុប ដែលសុទ្ធសឹងជាទីផ្សារធំៗសម្រាប់កម្ពុជា។ ទន្ទឹមនឹងនេះ កម្ពុជាក៏កាន់តែមានលទ្ធភាពធ្វើពិពិធកម្មទីផ្សារវាយនភណ្ឌទៅក្នុងតំបន់ផង និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជាកាន់តែកើនឡើងផង ដែលអាចធ្វើឱ្យមានការផ្ទេររោងចក្រពីបណ្តាប្រទេសក្នុងតំបន់មកកម្ពុជា។ លើសពីនេះ គម្រោងវិនិយោគមួយចំនួនក្នុងវិស័យអគ្គិសនី ទាំងវារីអគ្គិសនី ទាំងរោងចក្រអគ្គិសនីដើរដោយធ្យូងថ្ម នឹងចាប់ផ្តើមដំណើរការអាជីវកម្មកាន់តែច្រើនឡើង ស្របពេលនឹងគម្រោងផ្សេងៗទៀតក្នុងវិស័យរ៉ែ និងកម្មន្តសាល ពិសេសសកម្មភាពឧស្សាហកម្មក្នុងតំបន់សេដ្ឋកិច្ចពិសេសក៏នឹងចាប់ផ្តើមពង្រីកសកម្មភាពកាន់តែខ្លាំងក្លាជាងមុន។ វិស័យសេវាកម្មអាចនឹងសម្រេចបានកំណើនប្រមាណ៦,៣% ដោយសារតែចំនួនភ្ញៀវទេសចរនឹងបន្តកើនឡើង ពិសេសពីក្នុងតំបន់អាស៊ីដែលបាន និងកំពុងក្លាយជាតំបន់នាំមុខនៃសេដ្ឋកិច្ចសាកលលោក។ ទន្ទឹមនឹងនេះ វិស័យហិរញ្ញវត្ថុអាចនឹងមានសន្ទុះកាន់តែខ្លាំងឡើង ដើម្បីឆ្លើយតបទៅនឹង និងទ្រទ្រង់ដល់សកម្មភាពសេដ្ឋកិច្ចជាទូទៅ ស្របពេលនឹងការបង្កើតទីផ្សារមូលបត្រដែលនឹងជួយជំរុញសកម្មភាពហិរញ្ញវត្ថុឱ្យកាន់តែសកម្មថែមទៀត។ វិស័យអចលនវត្ថុ និងសំណង់ក៏រំពឹងថានឹងបន្តងើបឡើងវិញជាបណ្តើរៗ ដោយសារកំណើនចំណូលរបស់ប្រជាជន គោលនយោបាយជំរុញឱ្យមានការសាងសង់អគារខ្ពស់ៗ និងការអនុញ្ញាតឱ្យជនបរទេសមានកម្មសិទ្ធិលើអគារសហកម្មសិទ្ធិ។

៧- ក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ អតិផរណានៅកម្ពុជាបានរងឥទ្ធិពលពីកំណើនថ្លៃម្ហូបអាហារ ថ្លៃប្រេងឥន្ធនៈ និងថ្លៃវត្ថុធាតុដើមលើទីផ្សារអន្តរជាតិពិសេសតាមរយៈការនាំចូល ដែលឥទ្ធិពលនេះបានធ្វើឱ្យអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០០៨ ឡើងរហូតដល់១៩,៧%។ ប៉ុន្តែ ដោយសារការឆ្លើយតបទាន់ពេលវេលារបស់រាជរដ្ឋាភិបាលតាមរយៈការដាក់ចេញនូវវិធានការ និងគោលនយោបាយជាកញ្ចប់ប្រកបដោយប្រសិទ្ធភាព ជាពិសេសការអនុវត្តគោលនយោបាយហិរញ្ញវត្ថុសាធារណៈ និងគោលនយោបាយរូបិយវត្ថុដ៏សមស្រប និងប្រយ័ត្នប្រយែង អត្រាអតិផរណាបានធ្លាក់ចុះមកនៅក្នុងកម្រិតមួយសមស្រប និងអាចគ្រប់គ្រងបាន។ ជាក់ស្តែង

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ២០១១ បានធ្លាក់មកនៅត្រឹម៥,៥% ហើយតាមការព្យាករណ៍នៅឆ្នាំ២០១២ នេះ នឹងមានកម្រិតត្រឹមប្រមាណ៥% ដូចបានគ្រោងនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១២។ លើសពីនេះ ការសម្រេចចិត្តខាងនយោបាយរបស់ប្រមុខរាជរដ្ឋាភិបាល ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅវិស័យជលផល នៅក្នុងក្របខ័ណ្ឌទូទាំងប្រទេសនាពេលថ្មីៗនេះ មិនត្រឹមតែបានបង្កើនប្រសិទ្ធភាព និងសមធម៌ក្នុងអាជីវកម្មនេសាទ និងការអភិរក្សពូជត្រីប៉ុណ្ណោះទេ តែព្រមទាំងបាន និងកំពុងរួមចំណែកយ៉ាងខ្លាំងដល់ការកាត់បន្ថយសម្ពាធអតិផរណានៅកម្ពុជា និងធ្វើឱ្យអតិផរណាមានការធ្លាក់ចុះថែមទៀតផង។ តាមការព្យាករណ៍អត្រាអតិផរណានៅឆ្នាំ២០១៣ ខាងមុខ នឹងមានកម្រិតត្រឹមប្រមាណ៤% ដោយសារការលុបឡូតិ៍នេសាទទូទាំងប្រទេសនេះផង និងដោយសារនិន្នាការនៃការធ្លាក់ចុះនៃអត្រាអតិផរណារបស់បណ្តាប្រទេសជិតខាងផង។

៨- អត្រាប្តូរប្រាក់ត្រូវបានរក្សាឱ្យមានស្ថិរភាពល្អប្រសើរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ នៅឆ្នាំ២០១០ ប្រាក់រៀលមានតម្លៃជាមធ្យម៤ ១៧៤រៀល/ដុល្លារអាមេរិក ហើយនៅឆ្នាំ២០១១ មានតម្លៃ៤ ០៧៤រៀល/ដុល្លារអាមេរិក។ នៅដើមឆ្នាំ២០១២នេះ ប្រាក់រៀលបានឡើងថ្លៃដល់ប្រមាណ៤ ០៥០រៀល/ដុល្លារអាមេរិក ហើយតម្លៃប្រាក់រៀលនឹងបន្តស្ថិតក្នុងកម្រិតជាមធ្យមប្រមាណ៤ ០៥០រៀល/ដុល្លារអាមេរិក នៅក្នុងឆ្នាំ២០១២ នេះ និងឆ្នាំ២០១៣ ខាងមុខ។ អត្រាប្តូរប្រាក់នេះ មានកម្រិតទាបជាងអត្រាប្តូរប្រាក់ដែលបានកំណត់ចំនួន៤ ១០០រៀល/ដុល្លារអាមេរិក នៅក្នុង **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣»** ដោយសារការប្រែប្រួលនៃស្ថានភាពសេដ្ឋកិច្ចពិភពលោក និងការធ្លាក់ចុះនៃតម្លៃប្រាក់ដុល្លារអាមេរិក។ ការរក្សាស្ថិរភាពនៃអត្រាប្តូរប្រាក់នេះគឺជាយុទ្ធសាស្ត្របង្កើនទំនុកចិត្តមកលើប្រាក់រៀល បង្កើនតម្រូវការ និងចរាចរប្រាក់រៀល ដើម្បីកាត់បន្ថយដុល្លាររូបនីយកម្ម ហើយក៏ជួយរក្សាតុល្យភាពផលប្រយោជន៍រវាងអ្នកមានចំណូលជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិកផងដែរ។

៩- ឱនភាពគណនីចរន្តមាននិន្នាការថយចុះជាលំដាប់គឺពី-១០,១%នៃផសស នៅឆ្នាំ២០១០ មក -៧,៣%នៃផសស នៅឆ្នាំ២០១១។ តាមការព្យាករណ៍ ឱនភាពគណនីចរន្តនឹងបន្តធ្លាក់ចុះមកនៅត្រឹមតែ-៦% នៅឆ្នាំ២០១២ និង-៥,៨% នៅឆ្នាំ២០១៣។ និន្នាការនៃការធ្លាក់ចុះនេះ ដោយសារសមត្ថភាពនាំចេញរបស់កម្ពុជាមានការកើនឡើងជាលំដាប់ ទន្ទឹមនឹងផលិតផល និងវត្ថុធាតុដើមមួយចំនួនចាប់ផ្តើមមានមូលដ្ឋានផលិតនៅក្នុងស្រុកជំនួសឱ្យការនាំចូលជាបណ្តើរៗ។ ម្យ៉ាងទៀត សេដ្ឋកិច្ចកម្ពុជាបាននឹងកំពុងធ្វើសមាហរណកម្មយ៉ាងជិតស្និទ្ធទៅនឹងទីផ្សារ ដែលបាននឹងកំពុងផ្តល់ឱកាសដល់ការពង្រីកទំហំពាណិជ្ជកម្មដោយគ្មានដែនកំណត់។ ទុនបម្រុងអន្តរជាតិបានកើនឡើងពី២,៦៥ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១០ ដល់២,៩៧ពាន់លានដុល្លារអាមេរិកនៅឆ្នាំ២០១១។ ទុនបម្រុងអន្តរជាតិនឹងបន្តរក្សាបាននូវចលនាការកំណើនដដែល ដែលអាចធានាបាននូវការនាំចូលប្រមាណជាង៤ ខែ នៅក្នុងឆ្នាំ២០១២ និង២០១៣ខាងមុខនេះ។

១០- ក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចនេះ មានគោលបំណងធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច តាមរយៈការរក្សាកំណើនប្រកបដោយចីរភាព និងការធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងគ្រប់គ្រងស្ថិរភាពថ្លៃនៅលើទីផ្សារ និងចីរភាពបំណុលជាទូទៅ ដើម្បីសម្រេចបាននូវគោលដៅរយៈពេលមធ្យមនៃក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលដូចមានចែងក្នុង **«ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣»** ពោលគឺ

បន្តខិតខំដើម្បី (១)សម្រេចបាននូវអត្រាកំណើនជាមធ្យមប្រចាំឆ្នាំប្រមាណ៦-៧% (២)រក្សាអត្រាអតិផរណាឱ្យស្ថិតនៅក្រោម៥% (៣) កំណត់បំណុលបរទេសឱ្យមានកម្រិតប្រហាក់ប្រហែលនឹងលំហូរនៃហិរញ្ញប្បទាន និងការវិនិយោគផ្ទាល់ពីបរទេស និង (៤)រក្សាទុនបម្រុងអន្តរជាតិឱ្យស្មើនឹងការនាំចូលចំនួនបីខែ។ *ដើម្បីសម្រេចគោលបំណងខាងលើ រាជរដ្ឋាភិបាលកំណត់គោលដៅនៃកំណើនផលសរុបក្នុងស្រុក ឱ្យសម្រេចបានក្នុងរង្វង់៧% នៅឆ្នាំ២០១២ និងឆ្នាំ២០១៣ និងខិតខំគ្រប់គ្រងអតិផរណាមធ្យមប្រចាំឆ្នាំឱ្យស្ថិតក្នុងរង្វង់៥% ក្នុងឆ្នាំ២០១២ និង៤% ក្នុងឆ្នាំ២០១៣។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងធានារក្សាស្ថិរភាពអត្រាប្តូរប្រាក់រៀលឱ្យស្ថិតនៅក្នុងរង្វង់ជុំវិញ៤ ០៥០រៀល/ដុល្លារអាមេរិក ក្នុងគោលដៅជំរុញបដិដុល្លារូបនីយកម្មក្នុងរយៈពេលវែង ចំពោះមុខតាមរយៈការបង្កើនការប្រើប្រាស់ប្រាក់រៀល។* ផលសសម្រាប់មនុស្សម្នាក់នឹងកើនឡើងដល់ប្រមាណ៩៨៤ ដុល្លារអាមេរិក នៅឆ្នាំ២០១២នេះ និងប្រមាណ១ ០៦៧ ដុល្លារអាមេរិក នៅឆ្នាំ២០១៣ខាងមុខ។ លើសពីនេះ សម្រាប់រយៈពេលមធ្យមខាងមុខ(២០១៣-២០១៥) រាជរដ្ឋាភិបាលមានគោលដៅរក្សាកំណើនប្រចាំឆ្នាំឱ្យបានក្នុងរង្វង់ ៧% អត្រាអតិផរណាក្នុងរង្វង់ ៤% និងអត្រាប្តូរប្រាក់រៀលក្នុងរង្វង់៤ ០៥០រៀល។

ខ. <u>ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ</u>

១១- ដោយផ្អែកលើមូលដ្ឋាននៃ «**យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២**» និង «**ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣**» គោលនយោបាយហិរញ្ញវត្ថុសាធារណៈមានគោលដៅសំខាន់ៗដូចតទៅ ÷

- ធានាការបន្តអនុវត្ត **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ជាពិសេសការបន្តជំរុញការអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** *ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព* នៅកម្ពុជារបស់រាជរដ្ឋាភិបាលនីតិកាលទី៤នៃរដ្ឋសភា សំដៅសម្រេចគោលដៅនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- ធានាការបន្តអនុវត្តកម្មវិធីវិនិយោគសាធារណៈរំកិល៣ឆ្នាំ២០១៣-២០១៥។
- ធានាការអនុវត្តគោលនយោបាយអាទិភាពតាមវិស័យដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃ **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣** ដូចជា ÷
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់សេវាសាធារណៈនៅក្នុងវិស័យសង្គមកិច្ច ជាពិសេសវិស័យអប់រំ សុខាភិបាល និងសុវត្ថិភាពសង្គម។
  - ការបន្តផ្តល់អាទិភាពដល់ការបង្កើន និងលើកកម្ពស់សកម្មភាពដែលបម្រើឱ្យវិស័យសេដ្ឋកិច្ច ជាពិសេស វិស័យកសិកម្ម ធារាសាស្ត្រ ការកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអភិវឌ្ឍជនបទ។
- ធានាបន្តអនុវត្តកម្មវិធីកែទម្រង់ កម្មវិធីអភិវឌ្ឍន៍គ្រប់ការដ្ឋាន និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយស្តីពីការជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ។
- ធានាបន្តការពារឱ្យបានទាំងស្រុងនូវអធិបតេយ្យ និងបូរណភាពទឹកដី និងធានាបម្រើឱ្យការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដើម្បីបន្តរក្សាសន្តិភាព សន្តិសុខ សុវត្ថិភាព សេរីភាព ប្រជាធិបតេយ្យ និងសុភមង្គលជូនប្រជាពលរដ្ឋ ។

- ធានាផ្តល់ការឆ្លើយតបដោយទាន់ពេលវេលា និងដោយប្រសិទ្ធភាពចំពោះវិបត្តិ និងឧបទ្ទវហេតុផ្សេងៗ ដែលអាចកើតមានឡើងជាយថាហេតុ ដូចជាគ្រោះធម្មជាតិជាដើម។

១២- ដើម្បីឈានសម្រេចគោលដៅខាងលើនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់លើការធានាឱ្យបាននូវតុល្យភាពទាំងឥណទាន និងទាំងសាច់ប្រាក់ ។ ធ្វើដូចនេះ ដើម្បីរក្សាអតិរេកជាសាច់ប្រាក់សម្រាប់បំពេញតម្រូវការចំណាយឆ្នាំបន្ទាប់ និងសម្រាប់ត្រៀមបម្រុងទប់ទល់នឹងវិបត្តិដែលអាចកើតមានជាយថាហេតុពិសេសដើម្បីរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងភាពជឿទុកចិត្តនៃថវិកា ព្រមទាំងត្រៀមសម្រាប់បម្រើឱ្យការអនុវត្តគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ដែលនឹងត្រូវដាក់ចេញនាពេលខាងមុខ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងធានាឱ្យបាននូវសមតុល្យសាច់ប្រាក់ក្នុងចន្លោះពី១៥០ ទៅ២៥០ពាន់លានរៀល តាមរយៈការកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈដូចខាងក្រោម៖

- អតិរេកថវិកាចរន្តត្រូវធានាឱ្យបានក្នុងរង្វង់១,៨%នៃផសស សម្រាប់ឆ្នាំ២០១២ និង២,៦%នៃផសសសម្រាប់ឆ្នាំ២០១៣។ ឱនភាពថវិកាសរុបនឹងត្រូវកាត់បន្ថយពី-៧,៧%នៃផសស នៅឆ្នាំ២០១១មកនៅត្រឹម-៥,៩%នៃផសស នៅឆ្នាំ២០១២ និង-៤,៤%នៃផសស នៅឆ្នាំ២០១៣។
- ចំណូលសរុបនៅឆ្នាំ២០១២ ត្រូវសម្រេចឱ្យបាន១៣,៤%នៃផសស។ ក្នុងនោះ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវសម្រេចឱ្យបាន៦%នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបាន៥,១%នៃផសស ហើយចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន២,៣%នៃផសស។ ចំណូលសរុបសម្រាប់ឆ្នាំ២០១៣ ត្រូវសម្រេចឱ្យបានស្មើនឹង១៣,៨%នៃផសស។ ក្នុងនោះ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាត្រូវសម្រេចឱ្យបាន៦,៣%នៃផសស និងចំណូលពីអគ្គនាយកដ្ឋានពន្ធដារត្រូវសម្រេចឱ្យបាន៥,៣ %នៃផសស ហើយចំណូលមិនមែនសារពើពន្ធត្រូវសម្រេចឱ្យបាន២,២%នៃផសស។
- ចំណាយសរុបត្រូវរក្សាឱ្យនៅត្រឹម១៩,៣%នៃផសស នៅឆ្នាំ២០១២ ដោយចំណាយចរន្តត្រូវរក្សាឱ្យបានត្រឹម១១,៤% នៃផសស។ ចំណាយសរុបសម្រាប់ឆ្នាំ២០១៣ ត្រូវរក្សាឱ្យនៅត្រឹម១៨,២% នៃផសស ដោយចំណាយចរន្តនឹងកម្រិតត្រឹម១១,១%នៃផសស ដោយក្នុងនោះ កំណើនបៀវត្សមូលដ្ឋានសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធចំនួន២០% ត្រូវបានរក្សាដដែល។ ជាមួយគ្នានេះដែរចំណាយមូលធននឹងរក្សាស្មើនឹង៧,៨%នៃផសស នៅឆ្នាំ២០១២ និង៧,១% សម្រាប់ឆ្នាំ២០១៣។
- ជារួមសម្រាប់រយៈពេលមធ្យម (២០១៣-២០១៥) រាជរដ្ឋាភិបាលនឹងបន្តជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានលក្ខណៈកាន់តែស៊ីជម្រៅ ដើម្បីបន្តពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូលឱ្យបានតាមគោលដៅកំណើនចំណូលប្រចាំឆ្នាំប្រមាណ០,៥% នៃផសស និងបន្តពង្រឹងការរៀបចំ និងការអនុវត្តចំណាយឱ្យកាន់តែមានភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពក្នុងគោលដៅរក្សាឱនភាពថវិកាសរុបឱ្យស្ថិតក្នុងកម្រិតស្ថិរភាពគឺក្រោម៥% នៃផសស។

១៣- ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើនេះ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ដែលបានគូសបញ្ជាក់ខាងលើ ថវិកាឆ្នាំ២០១៣ ត្រូវគ្រោង និងរៀបចំឡើងលើគោលការណ៍**«បង្កើនការប្រមូលចំណូលបន្ថែមហើយពង្រឹងវិន័យ និងបង្កើនគុណភាពចំណាយ»** ដោយផ្អែកលើមូលដ្ឋានយុទ្ធសាស្ត្រ និងវិធានការដូចខាងក្រោម ÷

- បន្តពង្រឹងការគ្រប់គ្រងចំណូល និងជំរុញការប្រមូលចំណូល ជាពិសេស ការអនុវត្តឱ្យបានសម្រេចទៅតាមផែនការសកម្មភាព និងគោលដៅនៃសូចនាករនៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- បន្តពង្រឹងការរៀបចំថវិកាឱ្យកាន់តែមានភាពជាក់លាក់ ច្បាស់លាស់ និងសុក្រឹតភាព តាមរយៈការបន្តជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា ការរៀបចំគោលនយោបាយចំណូល និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមឱ្យបានច្បាស់លាស់ និងសុក្រឹត ការធ្វើសមាហរណកម្មថវិកា និងការបន្តកែលម្អការអនុវត្តថវិកាតាមកម្មវិធី។

- បន្តពង្រឹងការគ្រប់គ្រងចំណាយ ជាពិសេស បន្តពង្រឹង និងជំរុញការកែលម្អការអនុវត្តថវិកាតាមរយៈការបន្តកាត់បន្ថយនីតិវិធីចំណាយ ការបន្តពង្រឹងការគ្រប់គ្រងសាច់ប្រាក់ ការបន្តពង្រឹងការអនុវត្តកម្មវិធីចំណូល ចំណាយប្រចាំត្រីមាស ការបន្តត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងពាក់កណ្តាលឆ្នាំ ការបន្តពង្រឹងការអនុវត្តវិសហមជ្ឈការលទ្ធកម្មសាធារណៈ រឹតបន្តឹងការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ និងការបន្តពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅដើម្បីបន្តពង្រឹង ***ភាពជឿទុកចិត្តបាននៃថវិកា*** ដែលសម្រេចបាននៅក្នុងជំហានទី១ ដែលនឹងនៅតែជាមូលដ្ឋានដ៏សំខាន់ និងចាំបាច់សម្រាប់អនុវត្តកម្មវិធីជំហានទី២ ***គឺការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** និងបណ្តាជំហានបន្តបន្ទាប់ទៀត។

- បន្តពង្រឹង និងបង្កើនការអនុវត្តប្លង់គណនេយ្យថ្មី និងចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាថ្មី ប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យ និងហិរញ្ញវត្ថុឱ្យកាន់តែសុក្រឹត ព្រមទាំងការត្រួតពិនិត្យផ្ទៃក្នុង និងការត្រួតពិនិត្យផ្ទៃក្រៅ ជាពិសេសចាប់ផ្តើមកំណត់ និងដាក់ឱ្យអនុវត្តនូវចំណាត់ថ្នាក់មុខងារ អង្គភាពថវិកា បរិបថនិងនីតិវិធីអនុវត្តថវិកាថ្មី ដើម្បីឈានទៅអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធព័ត៌មានវិទ្យាដែលជាសកម្មភាពការងារដ៏ចំបងសម្រាប់សម្រេចជំហានទី២ គឺ***ការបង្កើនប្រសិទ្ធភាពនៃគណនេយ្យភាពហិរញ្ញវត្ថុ*** នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

- ចាប់ផ្តើមអនុវត្តផែនការយុទ្ធសាស្ត្រតាមប្រព័ន្ធព័ត៌មានវិទ្យា ជាពិសេស ខាងផ្នែកប្រមូលពន្ធដូចជាការផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម ការធ្វើអធិការកិច្ច និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា ។

- ពង្រឹងការគ្រប់គ្រងសហគ្រាសសាធារណៈ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ពិសេសការបង់ពន្ធ និងការបង់ចំណែកនៃប្រាក់ចំណេញជូនរដ្ឋ។

- បន្តស្រាវជ្រាវ និងកំណត់ឱ្យបានច្បាស់នូវបំណុលពាក់ព័ន្ធនឹងចំណូលមិនមែនសារពើពន្ធ ហើយបន្តជំរុញការអនុវត្តនូវផែនការសកម្មភាព និងបណ្តាវិធានការ ដើម្បីតឹងទារបំណុលតាមគ្រប់មុខសញ្ញាទាំងអស់។ ក្នុងនោះ ត្រូវផ្តោតការយកចិត្តទុកដាក់ ជាពិសេសទៅលើការគ្រប់គ្រងចំណូលពីប្រៃសណីយ៍ និងទូរគមនាគមន៍ អាកាសចរស៊ីវិល ចំណូលពីវិស័យទេសចរណ៍ ចំណូលទិដ្ឋាការ និងចំណូលពីការជួលរោងចក្រសហគ្រាស និងទ្រព្យសម្បត្តិរដ្ឋផ្សេងៗទៀត។

- បន្តការរឹតត្បិតចំណាយចរន្ត ដោយត្រូវប្រកាន់ខ្ជាប់នូវគោលការណ៍ធ្វើវិចារណកម្មចំណាយ និងការធ្វើអាទិភាវូបនីយកម្មចំណាយ ជាពិសេស ត្រូវបន្តពង្រឹងការគោរពវិន័យដប់មួយយ៉ាងគឺ ការអនុវត្តច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនឹងនេះ ត្រូវបន្តសន្សំសំចៃលើមុខសញ្ញាចំណាយអគ្គិសនី ទូរស័ព្ទ ប្រេងឥន្ធនៈ ជៀសវាងបេសកកម្មបរទេស ឬការចូលរួមប្រជុំនៅបរទេស ឬការរៀបចំប្រជុំនៅក្នុងប្រទេស

ដែលពុំសូវចាំបាច់ ការបញ្ឈប់ការទិញសម្ភារៈប្រណិត ការទិញសម្ភារៈថ្មី និងការបោះពុម្ពដែលពុំសូវចាំបាច់ ព្រមទាំងផ្អាកការសាងសង់អគារថ្មី ឬការជួសជុលដែលពុំចាំបាច់។

- អនុវត្តឱ្យបានម៉ឺងម៉ាត់នូវច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ពិសេសគឺត្រូវជំរុញការអនុវត្តទស្សនាទានស្តីពីតម្លៃនៃលុយដើម្បីបង្កើនគុណភាព និងប្រសិទ្ធភាពចំណាយ។
- បន្តពង្រឹងការគ្រប់គ្រង និងការជ្រើសរើសមន្ត្រីរាជការ ពិសេសបុគ្គលិកអណ្តែត និងមន្ត្រីជាប់កិច្ចសន្យា។

## III. សេចក្តីសន្និដ្ឋាន

១៤- ជារួម សេដ្ឋកិច្ចកម្ពុជាបានងើបឡើងវិញយ៉ាងល្អប្រសើរ ហើយកំពុងស្ថិតលើផ្លូវនៃកំណើនខ្ពស់ និងឈានទៅរកចីរភាព ទោះជាស្ថានភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុពិភពលោកស្ថិតក្នុងស្ថានភាពមិននឹងនទៅឡើយក្តី។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលបានកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ២០១៣ គឺកំណើនសេដ្ឋកិច្ចត្រូវសម្រេចឱ្យបានប្រមាណ៧% និងអត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ត្រូវរក្សាឱ្យស្ថិតក្នុងរង្វង់ដែលអាចគ្រប់គ្រងបានគឺក្នុងរង្វង់៤%។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់ឆ្នាំ២០១៣ ត្រូវបានកំណត់សម្រេចឱ្យបាននូវអតិរេកចរន្តក្នុងរង្វង់២,៦%នៃផសស ក្នុងនោះឱនភាពថវិកាសរុបនឹងត្រូវកាត់បន្ថយមកនៅត្រឹម-៤,៤%នៃផសស ហើយនឹងត្រូវកាត់បន្ថយជាលំដាប់នៅក្នុងរយៈពេលមធ្យមខាងមុខ ឆ្ពោះទៅរកកម្រិតចីរភាពនៃថវិកាគឺក្នុងរង្វង់៣%នៃផសស ដូចមុនពេលមានវិបត្តិឆ្នាំ២០០៩។

១៥- ការកំណត់គោលដៅ នៅក្នុងក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោល-នយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ គឺជាកត្តាគន្លឹះក្នុងការធានាបាននូវចីរភាពនៃកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ព្រមទាំងចីរភាព និងស្ថិរភាពនៃថវិកាដែលអាចឱ្យរាជរដ្ឋាភិបាលឈានទៅសម្រេចឱ្យបាននូវគោលដៅចម្បងនៃ **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២** ដែលជារបៀបវារៈគោលនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ចរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ នៃរដ្ឋសភាគឺ ***«ការធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ក្នុងរយៈពេលវែង មានអត្រាខ្ពស់ប្រមាណ៧%ក្នុងមួយឆ្នាំ នៅលើមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អត្រាអតិផរណាទាបក្នុងកម្រិតតួលេខមួយខ្ទង់ អត្រាប្តូរប្រាក់មានស្ថិរភាព និងមានកំណើនទុនបម្រុងជាប្រចាំ»*** និង***«ការធានាសម្រេចឱ្យបាននូវការកាត់បន្ថយអត្រានៃភាពក្រីក្រឱ្យបានលើស១%ក្នុងមួយឆ្នាំ និងការធានាកែលម្អសូចនាករសំខាន់ៗក្នុងវិស័យសង្គមកិច្ច ជាពិសេសក្នុងវិស័យអប់រំ សុខាភិបាល និងសមភាពយេនឌ័រ» និងឈានទៅសម្រេចបាននូវគោលដៅសហស្សវត្សរ៍កម្ពុជាទាំង៩*** ។ ទន្ទឹមនឹងនេះ ក្របខ័ណ្ឌគោលនយោបាយខាងលើក៏បានឆ្លុះបញ្ចាំងពីភាពចាំបាច់ក្នុងការខិតខំប្រឹងប្រែងបន្ថែមទៀតក្នុងការកៀរគរចំណូលទាំងចំណូលសារពើពន្ធ ទាំងចំណូលមិនមែនសារពើពន្ធ និងការធ្វើវិចារណកម្មចំណាយឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

## IV. សេចក្ដីណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា

១៦- ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១២-២០១៤របស់ខ្លួន និងក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈខាងលើ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃលើការអនុវត្តកន្លងមក ដើម្បីកែសម្រួល និងរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣-២០១៥ ទៅតាមគំរូដូចបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។ គំរូផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣-២០១៥ ដែលត្រូវបញ្ជូនមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនេះរួមមាន៦ផ្នែកគឺ៖

***ផ្នែកទី១: សេចក្ដីផ្ដើម*** គឺជាការរៀបរាប់អំពីមុខងារ និងភារកិច្ចរបស់ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្ត អំពីស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាក្នុងឆ្នាំកន្លងមក និងឆ្នាំកំពុងអនុវត្ត និងអំពីការចូលរួមចំណែកក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដើម្បីសម្រេចបាននូវគោលនយោបាយរួមរបស់រាជរដ្ឋាភិបាល ជាពិសេស យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ។

***ផ្នែកទី២: គោលបំណងគោលនយោបាយ*** គឺជាគោលបំណងគោលនយោបាយរយៈពេលមធ្យម (ពី៣ ទៅ៥ឆ្នាំ) ដែលត្រូវបានកំណត់ដោយក្រសួង ស្ថាប័ន ហើយដែលត្រូវបានរៀបចំនៅក្នុង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ ដែលជាយុទ្ធសាស្ត្រគោលនយោបាយដើម្បីអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ក្នុងគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកំពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ។

***ផ្នែកទី៣: កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព*** គឺជាកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលត្រូវបានរៀបចំឡើងដើម្បីអនុវត្តគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី២ ខាងលើ។ ការកំណត់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ គឺរួមមានទាំងកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពសម្រាប់ថវិកាជាតិ និងថវិកាផ្ដល់ដោយដៃគូអភិវឌ្ឍន៍ ដូចក្នុងតារាងទី៣.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។

***ផ្នែកទី៤: ការកំណត់សូចនាករ និងគោលដៅសូចនាករ*** គឺជាការកំណត់សូចនាករ និងគោលដៅសូចនាកររបស់កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ សម្រាប់តាមដាន និងវាស់លទ្ធផលសម្រេចបានពីការអនុវត្តកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗដែលបានរៀបចំ ដើម្បីសម្រេចបាននូវគោលដៅនៃគោលបំណងគោលនយោបាយរបស់ក្រសួង ស្ថាប័ន ដែលបានកំណត់។ សូចនាករនីមួយៗត្រូវមានការពន្យល់ពីមូលហេតុដែលត្រូវបានជ្រើសរើស បញ្ជាក់អំពីស្ថានភាពបច្ចុប្បន្ន កំណត់គោលដៅនៃលទ្ធផលក្នុងឆ្នាំនីមួយៗ និងកំណត់គោលដៅនៃលទ្ធផលចុងក្រោយ ដូចក្នុងតារាងទី៤.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយសារាចរណែនាំនេះ។

***ផ្នែកទី៥: ការកំណត់ធនធាន*** គឺជាការគ្រោងតម្រូវការចំណាយ និងចំណូលសម្រាប់រយៈពេល៣ឆ្នាំ(២០១៣-២០១៥) ហើយការគ្រោងនេះគឺត្រូវគិតបញ្ចូលទាំងថវិកាជាតិ និងថវិកាផ្ដល់ដោយដៃគូអភិវឌ្ឍន៍។ ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល៣ឆ្នាំ(២០១៣-២០១៥) ទៅតាមកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាពនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាផ្ដល់ដោយដៃគូអភិវឌ្ឍន៍ដូចក្នុងតារាងទី៥.១ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជា

មួយនឹងសារាចរណែនាំនេះ ។ ការគ្រោងចំណូល គឺជាការគ្រោងចំណូលសម្រាប់រយៈពេល៣ឆ្នាំ(២០១៣-២០១៥) ដោយផ្អែកលើក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើ ព្រមទាំងលទ្ធផល និងបទពិសោធន៍ក្នុងការអនុវត្តនៃបណ្តាឆ្នាំកន្លងមក រួមទាំងគោលនយោបាយ និងវិធានការថ្មីដែលគ្រោងនឹងដាក់ឱ្យអនុវត្ត។ ការគ្រោងចំណូលនេះ ត្រូវគិតបញ្ចូលគ្រប់ប្រភេទនៃចំណូលទាំងអស់ រួមទាំងចំណូលដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួងស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្ត និងចំណូលដែលបានមកពីដៃគូអភិវឌ្ឍន៍សម្រាប់អនុវត្តគម្រោងនៅក្នុងក្រសួងស្ថាប័នដូចក្នុងតារាងទី៥.២ នៃគំរូផែនការយុទ្ធសាស្ត្រថវិកាដែលបានភ្ជាប់មកជាមួយនឹងសារាចរណែនាំនេះ។

***ផ្នែកទី៦: សេចក្តីសន្និដ្ឋាន*** គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣ និងការលើកទិសដៅ កម្មវិធីសកម្មភាព និងវិធានការ ដើម្បីសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣ ។

១៧- ទទួលបានសារាចរណែនាំនេះ ក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានី ខេត្តទាំងអស់ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង ស្ថាប័ន និងមន្ទីរជំនាញរាជធានីខេត្តមានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេស ត្រូវទាក់ទងជាបន្ទាន់ជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ(នាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឱ្យបានទាន់ពេលវេលាតាមកាលកំណត់។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១២*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល</u>**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"***ដើម្បីជូនជ្រាប***"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង ស្ថាប័ន

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី ខេត្ត

"***ដើម្បីមុខការ***"

-ឯកសារ-កាលប្បវត្តិ

គំរូផែនការយុទ្ធសាស្ត្រថវិកាដែលភ្ជាប់នឹង
សារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៣

# ផែនការយុទ្ធសាស្ត្រថវិកា
# សម្រាប់ឆ្នាំ ២០១៣-២០១៥
# របស់ក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត.........

## I. សេចក្តីផ្តើម

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ដែលមាននៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិបច្ចុប្បន្នកម្មឆ្នាំ ២០០៩-២០១៣** ដែលជាយុទ្ធសាស្ត្រដើម្បីអនុវត្ត **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២** ដើម្បី ***កំណើន ការងារ សមធម៌*** និង ***ប្រសិទ្ធភាព*** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត........ មានគោលបំណងគោលនយោបាយដូចខាងក្រោម:

| គោលបំណងគោលនយោបាយ | ឆ្លើយតបទៅនឹងជ្រុងណាមួយនៃយុទ្ធសាស្ត្រចតុកោណនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ | ស្ថិតនៅក្នុងគោលនយោបាយតាមវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ទី១:................................ | | |
| ទី២:................................ | | |
| ......................................... | | |

## III. កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើអោយទទួលបានជោគជ័យក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត....... បានរៀបចំកម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ដែលមានដូចខាងក្រោម:

## តារាង ៣.១: កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព

គិតជាលានរៀ

| គោលបំណង<br>គោលនយោបាយ | កម្មវិធី<br>ឬ/និងយុទ្ធសាស្ត្រអាទិភាព | រយៈពេល<br>អនុវត្ត | តម្រូវការ<br>ថវិកាទានសរុប | ប៉ាន់ស្មានថវិកាទាន<br>បានអនុវត្តកន្លងមក<br>រហូតដល់ឆ្នាំ ២០១២ | តម្រូវការ<br>ថវិកាទានប |
|---|---|---|---|---|---|
| គោលបំណងគ.ប ទី ១:.................... | ១.១:.......................................................................................... | | | | |
| | ១.២:.......................................................................................... | | | | |
| | ១.៣:.......................................................................................... | | | | |
| គោលបំណងគ.ប ទី ២:.................... | ២.១:.......................................................................................... | | | | |
| | ២.២:.......................................................................................... | | | | |
| | ២.៣:.......................................................................................... | | | | |
| គោលបំណងគ.ប ទី ៣:.................... | ៣.១:.......................................................................................... | | | | |
| | ៣.២:.......................................................................................... | | | | |
| | ៣.៣:.......................................................................................... | | | | |
| ............................................. | .............................................................................................. | | | | |

## IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ

ក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត........បានកំណត់នូវសូចនាករ និង គោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាព និង សមិទ្ធិផលនៃការអនុវត្តកម្មវិធីឬយុទ្ធសាស្ត្រអាទិភាពនីមួយៗ ដូចខាងក្រោម៖

**តារាង ៤.១: ការកំណត់សូចនាករ និងគោលដៅសូចនាករ**

| កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព | ការកំណត់សូចនាករ | | ស្ថានភាពបច្ចុប្បន្ន | គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ | | | | គោលដៅ |
|---|---|---|---|---|---|---|---|---|
| | លទ្ធផលក្នុងឆ្នាំ | លទ្ធផលចុងក្រោយ | សូចនាករ លទ្ធផលក្នុងឆ្នាំ | ឆ្នាំ ២០១២ (ច្បាប់ហិ.) | ឆ្នាំ ២០១៣ (គ្រោង) | ឆ្នាំ ២០១៤ (គ្រោង) | ឆ្នាំ ២០១៥ (គ្រោង) | សូចនាករលទ្ធផល ចុងក្រោយ |
| ១.១:........................................ | | | | | | | | |
| ១.២:........................................ | | | | | | | | |
| ................................................ | | | | | | | | |
| ២.១:........................................ | | | | | | | | |
| ២.២:........................................ | | | | | | | | |
| ................................................ | | | | | | | | |
| ៣.១:........................................ | | | | | | | | |
| ៣.២:........................................ | | | | | | | | |
| ................................................ | | | | | | | | |

## V. ការកំណត់ធនធាន

### ការកំណត់តម្រូវការចំណាយ

**តារាង ៥.១: ការកំណត់តម្រូវការចំណាយ**

ឯកតាគិតជាលាន[illegible]

| គោលបំណងគោលនយោបាយ កម្មវិធី ឬ/និងយុទ្ធសាស្ត្រអាទិភាព ប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ ២០១២ | | | គ្រោងតម្រូវការផលាទានសម្រាប់ ឆ្នាំ ២០១៣ | | | គ្រោងតម្រូវការផលាទានសម្រាប់ ឆ្នាំ ២០១៤ | | | គ្រោងតម្រូវការផលាទានសម្រា[illegible] ឆ្នាំ ២០១៥ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ផ្សេ[illegible] |
| **សរុបរួម** | | | | | | | | | | | | |
| -សរុបចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -សរុបចំណាយមូលធន | | | | | | | | | | | | |
| +គម្រោងវិនិយោគ | | | | | | | | | | | | |
| គម្រោងមានហិរញ្ញប្បទាន | | | | | | | | | | | | |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| +ជំនួយបច្ចេកទេស | | | | | | | | | | | | |
| គម្រោងមានហិរញ្ញប្បទាន | | | | | | | | | | | | |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១. គោលបំណងគ.ប ទី ១ | | | | | | | | | | | | |
| -សរុបចំណាយចរន្ត | | | | | | | | | | | | |
| បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ក្រៅពីបន្ទុកបុគ្គលិក | | | | | | | | | | | | |
| -សរុបចំណាយមូលធន | | | | | | | | | | | | |
| +គម្រោងវិនិយោគ | | | | | | | | | | | | |
| គម្រោងមានហិរញ្ញប្បទាន | | | | | | | | | | | | |
| គម្រោងមិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| +ជំនួយបច្ចេកទេស | | | | | | | | | | | | |

| | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| គម្រោងមានហិរញ្ញប្បទាន<br>គម្រោងមិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១: កម្មវិធី-យុទ្ធសាស្ត្រអាទិភាពទី ១<br>-សរុបចំណាយចរន្ត<br>បន្ទុកបុគ្គលិក<br>ក្រៅពីបន្ទុកបុគ្គលិក<br>-សរុបចំណាយមូលធន<br>+គម្រោងវិនិយោគ<br>គម្រោងមានហិរញ្ញប្បទាន<br>គម្រោង:........................<br>.....................................<br>គម្រោងមិនទាន់មានហិរញ្ញប្បទាន<br>គម្រោង:........................<br>.....................................<br>+ជំនួយបច្ចេកទេស<br>គម្រោងមានហិរញ្ញប្បទាន<br>គម្រោង:........................<br>.....................................<br>គម្រោងមិនទាន់មានហិរញ្ញប្បទាន<br>គម្រោង:........................<br>..................................... | | | | | | | | | | | | |
| ១.២: កម្មវិធី-យុទ្ធសាស្ត្រអាទិភាពទី ២<br>.................................................<br>................................................. | | | | | | | | | | | | |

កំណត់សម្គាល់:

+ គម្រោងមានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងដំណើរការ និងគម្រោងដែលបានចុះកិច្ចសន្យារួច

+ គម្រោងមិនទាន់មានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងចរចារ និងគម្រោងកំពុងស្វែងរកហិរញ្ញប្បទាន

## ការគ្រោងចំណូល

ដើម្បីរួមចំណែកដល់ការខិតខំរបស់រាជរដ្ឋាភិបាលក្នុងការប្រមូលធនធានដើម្បីសំរេចឱ្យបាននូវក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលបានកំណត់ ក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត......... បានដាក់ចេញនូវយុទ្ធសាស្ត្រមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម៖

ក..................................................

ខ..................................................

តាមរយៈយុទ្ធសាស្ត្រនេះ ក្រសួង-ស្ថាប័ន/មន្ទីរជំនាញរាជធានី-ខេត្ត............. បានគ្រោងចំណូលដូចខាងក្រោម៖

**តារាង ៥.២៖ ការគ្រោងចំណូល**

ឯកតាគិតជាលានរៀល

| ប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១២ | | គ្រោងឆ្នាំ ២០១៣ | | គ្រោងឆ្នាំ ២០១៤ | | គ្រោងឆ្នាំ ២០១៥ | |
|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍន៍ | ថវិការដ្ឋ | ថវិកាដៃគូអភិវ |
| សរុបរួម | | | | | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>-ចំណូលសារពើពន្ធ<br>-ចំណូលមិនមែនសារពើពន្ធ<br>-ចំណូលមូលធនក្នុងស្រុក (កម្ចីបន្ត) | | | | | | | | |
| ២. ចំណូលពីការអនុវត្តកម្មវិធី/គម្រោង<br>- គម្រោងវិនិយោគ (មានហិរញ្ញប្បទាន)<br>- ជំនួយបច្ចេកទេស (មានហិរញ្ញប្បទាន) | | | | | | | | |

VI. សេចក្តីសន្និដ្ឋាន

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

..................................................................................................................................................................

រាជធានីភ្នំពេញ, ថ្ងៃទី............ខែ................ឆ្នាំ....................

រដ្ឋមន្ត្រី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# តារាងគំរូគម្រោងចំណាយសម្រាប់ឆ្នាំ២០១៣

| ល.រ | ចំណាត់ថ្នាក់ចំណាយ | សរុបមូលដ្ឋានគិតចំណាយ ( មកដល់បច្ចុប្បន្ន) | | គម្រោងឆ្នាំ២០១៣ | | |
|---|---|---|---|---|---|---|
| | | មូលដ្ឋានគិត | បរិមាណ | មូលដ្ឋានគិតចំណាយ ( ដោយបង្ហាញការគណនាក្នុង ១ ឯកតា) | សរុបមូលដ្ឋានគិតចំណាយ | ចំនួនទឹកប្រាក់សរុបជារៀល |
| | | | | | | |
| I | *ចំណាយចរន្ត* | | | | | |
| 01 | | | | | | |
| 02 | | | | | | |
| 03 | | | | | | |
| 04 | | | | | | |
| - | | | | | | |
| - | | | | | | |
| - | | | | | | |
| - | | | | | | |
| II | ចំណាយមូលធន | | | | | |
| 01 | | | | | | |
| 02 | | | | | | |
| 03 | | | | | | |
| 04 | | | | | | |
| - | | | | | | |
| - | | | | | | |
| - | | | | | | |
| - | | | | | | |

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ ២០១២

អ្នកធ្វើតារាង

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ,ថ្ងៃទី ខែ ឆ្នាំ២០១២

**ប្រធានអង្គភាព**